**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

364
07/03/18

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ**
**នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ**
(កាំកុងត្រូល)

លេខ: ១៤៥ អ.តពទ
 ៧៣

# របាយការណ៍
## ស្តីពីសកម្មភាពការងារ របស់អគ្គនាយកដ្ឋាន
## កម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)
## ប្រចាំខែកុម្ភៈ ឆ្នាំ២០១៨ និងទិសដៅអនុវត្តខែបន្ទាប់

ដើម្បីកសាងបាននូវលទ្ធភាព នៃការប្រកួតប្រជែងក្នុងពាណិជ្ជកម្ម និងបំពេញបាននូវគោលបំណងនៃកិច្ចសម្រួលពាណិជ្ជកម្ម លើកកម្ពស់ផលិតកម្ម អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) មានតួនាទីធានាគុណភាពនៃផលិតផលឱ្យសមស្របតាមស្តង់ដារ និងតម្រូវការរបស់ទីផ្សារ ការការពារកម្មសិទ្ធិបញ្ញា ការទប់ស្កាត់ការក្លែងបន្លំ ធានាគុណភាពឱ្យការនាំចេញ ក៏ដូចជាការប្រើប្រាស់ក្នុងស្រុក ជៀសវាងផលប៉ះពាល់ដល់សុវត្ថិភាព និងផលប្រយោជន៍របស់អ្នកប្រើប្រាស់។

ក្នុងខែកុម្ភៈ ឆ្នាំ២០១៨ អគ្គនាយកដ្ឋានកាំកុងត្រូល បានខិតខំអនុវត្តភារកិច្ចរបស់ខ្លួនសម្រេចបានលទ្ធផលដូចខាងក្រោម ៖

**១. ការត្រួតពិនិត្យការនាំចេញ-នាំចូល តាមច្រកព្រំដែន**

គោលបំណងទប់ស្កាត់ការនាំចូល-នាំចេញទំនិញពុំសមស្រប តាមបញ្ញត្តិបច្ចេកទេស ពាក់ព័ន្ធនឹងគុណភាពសុវត្ថិភាពផលិតផល និងគោលនយោបាយពាណិជ្ជកម្ម ក្នុងទិសដៅរួមគឺ ការពារអ្នកប្រើ ការពារការធ្វើពាណិជ្ជកម្មឱ្យមានសមធម៌ និងការពារកេរ្តិ៍ឈ្មោះផលិតផលកម្ពុជា នៅលើទីផ្សារអន្តរជាតិ ។

អគ្គនាយកដ្ឋានកាំកុងត្រូល បានដំណើរការត្រួតពិនិត្យទំនិញនាំចេញ-នាំចូលតាមច្រកទ្វារព្រំដែន ដោយមានការគាំទ្រដោយរថយន្តពិសោធន៍ចល័ត ធ្វើការវិភាគផលិតផលទំនិញនៅច្រកទ្វារព្រំដែនផ្ទាល់ និងយកគំរូបញ្ជូនមក វិភាគនៅមន្ទីរពិសោធន៍របស់អគ្គនាយកដ្ឋានផងដែរ ។

<u>លទ្ធផល</u> : បានរកឃើញ ឃាត់ទុក ឬកំទេចចោល ផលិតផលខូចគុណភាពមួយចំនួនដូចខាងក្រោម ៖

+ សាច់-ឆ្អឹងមាន់ ចំនួន ៥៩៧ គីឡូក្រាម នៅខេត្តបាត់ដំបង និងបន្ទាយមានជ័យ
+ កំទេចនំ-កំទេចមី - ២៣៥ គីឡូក្រាម នៅខេត្តបាត់ដំបង
+ វត្ថុធាតុដើមផលិតឡេលាបស្បែក - ៨៧ គីឡូក្រាម នៅខេត្តបន្ទាយមានជ័យ

**២. ការត្រួតពិនិត្យពាណិជ្ជកម្ម** (**ភាគីទី ៣**)

ក្រៅពីការអនុវត្តន៍សកម្មភាពត្រួតពិនិត្យជាលក្ខណៈផ្លូវច្បាប់ អគ្គនាយកដ្ឋានត្រូវបានទទួលអាណត្តិផ្តល់សេវាត្រួតពិនិត្យពាណិជ្ជកម្មលក្ខណៈជាភាគីទី ៣ ដែលជាសកម្មភាពមួយ បំពេញឱ្យតម្រូវការក្នុងកិច្ចសម្រួលពាណិជ្ជកម្មផងដែរ ។